១៦- លោក គង់ ជាវ័ន្ត	អនុមន្ត្រី	ថ្នាក់លេខ ៤
១៧- លោកស្រី ពិជោរ សុវណ្ណនិកា	អនុមន្ត្រី	ថ្នាក់លេខ ៤
១៨- លោក ស៊ិន សុខ	អនុមន្ត្រី	ថ្នាក់លេខ ៤
១៩- លោកស្រី តាន់ ស៊ាវមី	អនុមន្ត្រី	ថ្នាក់លេខ ៤
២០- លោកស្រី ចាន់ ផល្លីកា	អនុមន្ត្រី	ថ្នាក់លេខ ៤
២១- លោកស្រី ហេង ស្រស់	អនុមន្ត្រី	ថ្នាក់លេខ ៤
២២- លោក ជាន់ ច័ន្ទសម្បត្តិ	អនុមន្ត្រី	ថ្នាក់លេខ ៤
២៣- លោកស្រី អ៊ុង អង្គារវិមាន	អនុមន្ត្រី	ថ្នាក់លេខ ៤
២៤- លោកស្រី ទូ សុខា	អនុមន្ត្រី	ថ្នាក់លេខ ៤
២៥- លោក មឿន ពន្លក	អនុមន្ត្រី	ថ្នាក់លេខ ៤
២៦- លោក ចាយ សុជាតិ	អនុមន្ត្រី	ថ្នាក់លេខ ៤
២៧- លោក ម្ងៀប សុវណ្ណា	អនុមន្ត្រី	ថ្នាក់លេខ ៤
២៨- លោកស្រី ចាន់ ថុនបញ្ញា	អនុមន្ត្រី	ថ្នាក់លេខ ៤
២៩- លោកស្រី អ៊ូ គឹមឡេន	អនុមន្ត្រី	ថ្នាក់លេខ ៤
៣០- លោក សង្ហាត ឥន្ទ្រនៈ	អនុមន្ត្រី	ថ្នាក់លេខ ៤
៣១- លោកស្រី តាវ រដ្ឋា	អនុមន្ត្រី	ថ្នាក់លេខ ៤

៣២- លោកស្រី ហាស សុខរុន	អនុមន្ត្រី	ថ្នាក់លេខ ៤
៣៣- លោកស្រី ផន ស្រីនី	អនុមន្ត្រី	ថ្នាក់លេខ ៤
៣៤- លោក ម៉ក់ ហ៊ាងរិទ្ធី	អនុមន្ត្រី	ថ្នាក់លេខ ៤
៣៥- លោកស្រី ព្រ្ចុ សុគន្ធា	អនុមន្ត្រី	ថ្នាក់លេខ ៤
៣៦- លោក សុខ ឆារិទ្ធ	អនុមន្ត្រី	ថ្នាក់លេខ ៤
៣៧- លោកស្រី ឃុន មល្លិកា	អនុមន្ត្រី	ថ្នាក់លេខ ៤
៣៨- លោក ង៉ាត ឌុន្នី	អនុមន្ត្រី	ថ្នាក់លេខ ៤
៣៩- លោក យន់ សីហា	អនុមន្ត្រី	ថ្នាក់លេខ ៤
៤០- លោក ស្រេង រដ្ឋា	អនុមន្ត្រី	ថ្នាក់លេខ ៤
៤១- លោក អ៊ូច សៀកហុង	អនុមន្ត្រី	ថ្នាក់លេខ ៤
៤២- លោកស្រី ឆោម ពៅពិសី	អនុមន្ត្រី	ថ្នាក់លេខ ៤
៤៣- លោកស្រី ម៉ូ ពេជ្រធីតា	អនុមន្ត្រី	ថ្នាក់លេខ ៤
៤៤- លោក ឌុ្ឍត សុខុម	អនុមន្ត្រី	ថ្នាក់លេខ ៤
៤៥- លោកស្រី ទូច ស្រីនិច្ច	អនុមន្ត្រី	ថ្នាក់លេខ ៤
៤៦- លោក គឹម សាមីឌី	អនុមន្ត្រី	ថ្នាក់លេខ ៤
៤៧- លោក គង់ ឥសាល	អនុមន្ត្រី	ថ្នាក់លេខ ៤
៤៨- លោកស្រី ជ៉ាវ ទិត្យាវី	អនុមន្ត្រី	ថ្នាក់លេខ ៤
៤៩- លោកស្រី ជឹម លីម	អនុមន្ត្រី	ថ្នាក់លេខ ៤
៥០- លោកស្រី ទេព ស្រីណា	អនុមន្ត្រី	ថ្នាក់លេខ ៤
៥១- លោកស្រី សែម សុគន្ធា	អនុមន្ត្រី	ថ្នាក់លេខ ៤
៥២- លោកស្រី ឌុ្ឍត សុតា	អនុមន្ត្រី	ថ្នាក់លេខ ៤
៥៣- លោក ជាន់ ១ុំ	អនុមន្ត្រី	ថ្នាក់លេខ ៤
៥៤- លោក សាយ សុជាតិ	អនុមន្ត្រី	ថ្នាក់លេខ ៤
៥៥- លោក ចំរើន រស្មី	អនុមន្ត្រី	ថ្នាក់លេខ ៤
៥៦- លោកស្រី ជួន ឥសាខា	អនុមន្ត្រី	ថ្នាក់លេខ ៤
៥៧- លោកស្រី អេង ស៊ីណា	អនុមន្ត្រី	ថ្នាក់លេខ ៤
៥៨- លោកស្រី យ៉ោន សុជាតិ	អនុមន្ត្រី	ថ្នាក់លេខ ៤
៥៩- លោក ស្ពុក ម៉ាឡា	អនុមន្ត្រី	ថ្នាក់លេខ ៤
៦០- លោក អេង សុម៉ាច	អនុមន្ត្រី	ថ្នាក់លេខ ៤

៦១- លោកស្រី **ឌណ្ណា នារ៉ា**	អនុមន្ត្រី	ថ្នាក់លេខ ៤
៦២- លោក **ឈិត ពៅ**	អនុមន្ត្រី	ថ្នាក់លេខ ៤
៦៣- លោកស្រី **ឌាច ឈុនម៉ា**	អនុមន្ត្រី	ថ្នាក់លេខ ៤
៦៤- លោកស្រី **ង៉ូ ឆោមម្លា**	អនុមន្ត្រី	ថ្នាក់លេខ ៤
៦៥- លោក **ម៉ឹង ហាស**	អនុមន្ត្រី	ថ្នាក់លេខ ៤
៦៦- លោក **ស្រ៊ុន ប៉េងឈាង**	អនុមន្ត្រី	ថ្នាក់លេខ ៤
៦៧- លោក **ហាក់ ច័ន្ទសុតារ៉ូ**	អនុមន្ត្រី	ថ្នាក់លេខ ៤
៦៨- លោកស្រី **ម៉ូច ជាវី**	អនុមន្ត្រី	ថ្នាក់លេខ ៤
៦៩- លោក **ឃូ ធីធី**	អនុមន្ត្រី	ថ្នាក់លេខ ៤
៧០- លោក **គឹម សុភក្តី**	អនុមន្ត្រី	ថ្នាក់លេខ ៤
៧១- លោក **ឌី ពិសិដ្ឋ**	អនុមន្ត្រី	ថ្នាក់លេខ ៤
៧២- លោកស្រី **ស៊ិន សុវ៉ាន់**	អនុមន្ត្រី	ថ្នាក់លេខ ៤
៧៣- លោកស្រី **ស៊ឹម ស៊ីភ័ក្ត**	អនុមន្ត្រី	ថ្នាក់លេខ ៤
៧៤- លោកស្រី **វ៉ាន ស្រីអែម**	អនុមន្ត្រី	ថ្នាក់លេខ ៤
៧៥- លោកស្រី **ធឿន ច័ន្ទរ៉ូ**	អនុមន្ត្រី	ថ្នាក់លេខ ៤
៧៦- លោកស្រី **ស៊ាន សុគន្ធារី**	អនុមន្ត្រី	ថ្នាក់លេខ ៤
៧៧- លោកស្រី **ឈុំ ម៉ុំ**	អនុមន្ត្រី	ថ្នាក់លេខ ៤
តាំងសម្រាប់ចាប់ពីថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៨		
៧៨- លោក **ម៉ែត សុបញ្ញា**	អនុមន្ត្រី	ថ្នាក់លេខ ៤

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆការ
នរោត្តម សីហមុនី

លេខ:៨៤៤៧ ស.ណ

សំណៅដែលមានតម្លៃជាការចែកផ្សាយ
ថ្ងៃពុធ ១២រោចខែទុតិយាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
ភ្នំពេញ ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៨
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

ឯកសារ.១៨០៨.៨៣០

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១៨

ព្រះរាជក្រឹត្យ

នស/រកត/០៨១៨/៨១៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សម្តេចតូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ងួហោតាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខណ្ឌិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខណ្ឌិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈ:របស់រដ្ឋ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : និយ័តកម្ម តម្លើងក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់ ពីក្របខ័ណ្ឌមន្ត្រីក្រមការ មកជាក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ដល់មន្ត្រីរាជការ ០៤ រូប ៖

១- លោក **ធិត្យ សារ៉ូ**	ពីនាយក្រមការ ថ្នាក់លេខ ១	មកជានាយ្ត្ត្ត

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ

សំណុំរឿង

លេខ : ៣៥៤/០០៥/២០១៨

ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៨

សេចក្តីសម្រេច

លេខ : ១៩៦/០០៤/២០១៨ កបធ.ច

ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៨

ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៨/០០៥ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ មាត្រា ២៧ ថ្មី មាត្រា ២៨ មាត្រា ៣១ និងមាត្រា ៣២ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៥/០០៣ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

-បានឃើញ ពាក្យបណ្តឹងរបស់ឈ្មោះ **ជា ជីវ** ឈ្មោះ **ថោង សារ៉ៃន** និងឈ្មោះ **ក្រុយ គឹមសាំង** ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៨ ដែលមានលោកមេធាវី **សំ សុគង់** ជាអ្នកតំណាងដោយអាណត្តិ ប្តឹងជំទាស់នឹងសេចក្តីសម្រេចលេខ ០០៩ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៨ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

-បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់លោកមេធាវី **សំ សុគង់** កាលពីថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៨ នៅចំពោះមុខក្រុមទី២ នៃក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញលិខិតលេខ ១២៧៧ គ.ជ.ប ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៨ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតឧទ្ទេសនាម ឯកឧត្តម **មាន សទិ** ឯកឧត្តម **កែ រ៉ីទ្ធិ** និងលោក **ហួត បូរិន** មកបំភ្លឺនៅចំពោះមុខក្រុមទី២ នៃក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់ឯកឧត្តម **មាន សទិ** ឯកឧត្តម **កែ រ៉ីទ្ធិ** និង លោក **ហួត បូរិន** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត នៅចំពោះមុខក្រុមទី២ នៃក្រុមប្រឹក្សាធម្មនុញ្ញ កាលពីថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៨ ភ្ជាប់ដោយសារណាចំនួន ០៤ទំព័រ ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៨

-បានឃើញកំណត់ហេតុ និងរបាយការណ៍ស៊ើបអង្កេតដល់ទីកន្លែងរបស់មន្ត្រីជំនាញនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៨

-នៅពេលឆ្លើយបំភ្លឺចំពោះមុខក្រុមទី២ នៃក្រុមប្រឹក្សាធម្មនុញ្ញ លោកមេធាវី **សំ សុគង់** បានបញ្ជាក់ថា « ខ្ញុំមិនមានអ្វីបន្ថែមទេចំពោះពាក្យបណ្តឹងដែលបានដាក់នៅក្រុម-ប្រឹក្សាធម្មនុញ្ញ កាលពីថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៨។ ទាក់ទងនឹងភស្តុតាងខ្ញុំបានដាក់ភស្តុតាងជារូបភាពភ្ជាប់មកជាមួយនឹងពាក្យបណ្តឹងដែលជារូបភាពរបស់កូនក្តីរបស់ខ្ញុំបានបង្ហោះក្នុងហ្វេសបុកហើយចំពោះសាក្សី និងភស្តុតាងបន្ថែមប្រហែលជាគ្មានទេ បើមានខ្ញុំនឹងយកមកបន្ថែមក្នុងថ្ងៃបើកសវនាការតែម្តង។ ខ្ញុំសូមសំណូមពរឱ្យក្រុមប្រឹក្សាធម្មនុញ្ញច្រានចោលសេចក្តីសម្រេចលេខ ០០៩ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៨ របស់ គ.ជ.ប និងសូមឱ្យកូនក្តីរបស់ខ្ញុំរួចផុតពីការពិន័យពីព្រោះ កូនក្តីខ្ញុំមានជីវភាពក្រីក្រ ពុំមានលទ្ធភាពក្នុងការបង់ប្រាក់ពិន័យបានទេ។ »

-នៅពេលសវនាការជំនុំជម្រះសាធារណៈលោកមេធាវី **សំ សុគង់** បានថ្លែងថាចំណុចសំខាន់ៗមានក្នុងសារណាការពារ ដែលមានខ្លឹមសារសង្ខេបដូចខាងក្រោម៖

-សុំលុបចោលសេចក្តីសម្រេចលេខ ០០៩ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៨ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ហើយសុំឱ្យកូនក្តីខ្ញុំនរួចផុតពីការជាកពិន័យ

-ទទួលស្គាល់នូវអង្គហេតុ៖

• នៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៨ កូនក្តីខ្លួនទាំង៥នាក់ និងប្រជាពលរដ្ឋមួយចំនួនបានមកជួបជុំគ្នានៅផ្ទះលោក **ជា ជីវ** គោលបំណងជួបជុំគ្នាពិសានំបញ្ចុក ដែលគ្រួសារលោក **ជា ជីវ** មានបំណងដង្ហែទៀនវស្សាទៅវត្ត

• ក្រោយពីពិសានំបញ្ចុករួចកូនក្តីខ្លួន និង ប្រជាពលរដ្ឋមួយចំនួនទៀតបានថតរូបជុំគ្នាដោយបានលើកម្រាមដៃចង្អុលទៅលើមេយ ដើម្បីថតទុកជាអនុស្សាវរីយ៍ និងបង្ហាញពីឆន្ទៈផ្ទាល់ខ្លួនថាខ្លួនប្រើប្រាស់សិទ្ធិពលរដ្ឋ និងមិនទៅបោះឆ្នោតនៅថ្ងៃបោះឆ្នោតជាតិ ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៨ ខាងមុខ

• ក្រោយមកកូនក្តីខ្លួន លោក **ជា ជីវ** លោក **ថោង សារឿន** និងលោក **ត្រុយ គឹមសាំង** បានយករូបភាពមកបង្ហោះតាមបណ្តាញសង្គមហ្វេសបុកដោយដាក់ចំណងជើងថា "ម្រាមដៃខ្ញុំត្រូវតែស្អាត បើគ្មានគណបក្សសង្គ្រោះជាតិ ម្រាមដៃស្អាត ចិត្តជ្រះថ្លា មិនលក់មនសិការ និងម្រាមដៃយើងខ្ញុំពិតជាស្អាតណាស់..."

-ការលើកម្រាមដៃ និងការជួបជុំគ្នាញ៉ាំនំបញ្ចុកមិនបានហាមឃាត់ដោយបញ្ញត្តិច្បាប់ណាមួយទេ គឺជាការប្រើប្រាស់សិទ្ធិពលរដ្ឋក្នុងសកម្មភាព និងជីវភាពនយោបាយ ចំពោះសិទ្ធិបញ្ចេញមតិ និងសិទ្ធិជួបប្រជុំគ្នាដែលធានាដោយរដ្ឋធម្មនុញ្ញ និងមាត្រា ១៩ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

-កូនក្តីខ្លួនមិនបានទទួលបញ្ជាពីនរណាមួយឡើយ ហើយកូនក្តីខ្លួនជាប្រជាពលរដ្ឋសាមញ្ញ លែងជាសកម្មជនគណបក្សនយោបាយណាមួយទៀតឡើយ ដោយសារតុលាការកំពូលបានចេញសាលដីការំលាយគណបក្សកាលពីអំឡុងចុងឆ្នាំ២០១៧ ម្ល៉េះ

-យុទ្ធនាការម្រាមដៃស្អាត និងយុទ្ធនាការដេកផ្ទះឈ្នះឯង គឺមិនមែនយុទ្ធនាការខុសច្បាប់ ឬជាសកម្មភាពខុសច្បាប់ទេ ដោយសារមិនមានច្បាប់ ឬសេចក្តីសម្រេចរបស់អាជ្ញាធរណាមួយអះអាងថា សកម្មភាពនេះ ខុសច្បាប់ផងដែរ។ ដោយសារ

យល់ឃើញថា មិនខុសច្បាប់បែបនេះហើយទើបកូនក្តីខ្លួន ថតរូបជុំគ្នាលើកម្រាមដៃ ចង្អុលមេយ ថាជាសកម្មភាពមិនខុសច្បាប់ និងជាការប្រើប្រាស់សិទ្ធិ

-សកម្មភាពនេះមិនបណ្តាលឱ្យមានព្យសនកម្មដល់អត្រានៃអ្នកទៅបោះឆ្នោតឡើយ

-គួលេខអ្នកចេញទៅបោះឆ្នោតជាយថាហេតុ គឺតែងតែប្រែប្រួលពីអាណត្តិមួយទៅអាណត្តិមួយ

-សន្លឹកឆ្នោតមិនបានការមិនមែនកើតឡើងពីសកម្មភាពរបស់កូនក្តីខ្លួនឡើយ

-ការបង្ហោះរូបភាពលើកម្រាមដៃឡើងលើមេយ និងបានដាក់ចំណងជើងថា "ម្រាមដៃខ្ញុំត្រូវតែស្អាត បើគ្មានគណបក្សសង្គ្រោះជាតិ ម្រាមដៃស្អាត ចិត្តជ្រះថ្លា មិនលក់មនសិការ និងម្រាមដៃយើងខ្ញុំពិតជាស្អាតណាស់..." មិនឃើញមានខ្លឹមសារ ឬពាក្យណាមួយជាការអំពាវនាវ ឬរារាំងមិនឱ្យប្រជាពលរដ្ឋ មិនចេញទៅបោះឆ្នោតនោះទេ ព្រោះនេះជាការប្រើប្រាស់សិទ្ធិខ្លួនឯង មិនមែនជាអំពើសកម្មទៅលើអ្នកណាផ្សេងក្រៅពីខ្លួនឯង

-ការយកអង្គហេតុរបស់លោក **សម រង្ស៊ី** និងយកអង្គហេតុរបស់លោកមេធាវី **ជួង ជូឌី** មកភ្ជាប់ជាមួយអង្គហេតុកូនក្តីខ្លួន គឺមិនទាន់ត្រឹមត្រូវ និងមានការភាន់ច្រឡំ ដោយសារអង្គហេតុកូនក្តីខ្លួនបានប្រើសិទ្ធិពលរដ្ឋក្នុងការចូលរួមក្នុងសកម្មភាពនយោបាយ ដែលធានាដោយមាត្រា ៤១ និងមាត្រា ៤២ នៃរដ្ឋធម្មនុញ្ញ

- ក្នុងមាត្រា ១៤២ វាក្យខណ្ឌទី៥ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ "រារាំងប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោត មិនឱ្យទៅបោះឆ្នោត" ក្នុងស្មារតីនៃមាត្រានេះ សំដៅដល់សកម្មភាពសកម្មណាមួយនៅក្នុងអំឡុងពេលបោះឆ្នោត ដោយសារតែការគំរាមកំហែង ការប្រើហិង្សា និងរារាំងណាមួយនៅពេលបោះឆ្នោត

-ការប្រើប្រាស់សិទ្ធិរបស់កូនក្តីខ្លួន ផ្អែកតាមមាត្រា ៤១ នៃរដ្ឋធម្មនុញ្ញ មិនបានប៉ះពាល់ដល់សិទ្ធិរបស់អ្នកដទៃនោះទេ។ កូនក្តីខ្លួនបានបង្ហោះរូបថតកាលពីថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៨ និងការបោះឆ្នោតនៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៨ សកម្មភាពនេះមិនស្មើសនឹងមាត្រា ១៤២ ទេ

- កូនក្តីរបស់ខ្លួនជាពលរដ្ឋសាមញ្ញ មិនយល់ពីច្បាប់ទេ ដូច្នេះពុំគប្បីទទួលខុសត្រូវចំពោះមុខច្បាប់ឡើយ

-លោកមេធាវី **កែត ឃី** បានលើកឡើងថា អ្នកប្តឹងត្រូវខូចប្រយោជន៍ទើបមានគុណសម្បត្តិក្នុងការប្តឹង ប៉ុន្តែក្នុងរឿងនេះគណបក្សប្រជាជនខេត្តបាត់ដំបងដែលដាក់ពាក្យបណ្តឹងតាមរយៈលោកមេធាវី **ហាម មុនី** មិនមានខូចប្រយោជន៍ទេ

-លោកមេធាវីតំណាងដោយអាណត្តិរបស់ឈ្មោះ **ជា ជីវ** ឈ្មោះ **ថោង សារឿន** និងឈ្មោះ **ត្រុយ គឹមសាំង** សំណូមពរក្រុមប្រឹក្សាជំនុំជម្រះនៃក្រុមប្រឹក្សាធម្មនុញ្ញលុបចោលសេចក្តីសម្រេចលេខ ០០៩ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៨ ត្រង់ចំណុចជាកពិន័យចំពោះកូនក្តីខ្លួន

-នៅពេលឆ្លើយបំភ្លឺចំពោះមុខក្រុមទី២ នៃក្រុមប្រឹក្សាធម្មនុញ្ញ ឯកឧត្តម **មាន សទិ** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានបញ្ជាក់ថា "ចំពោះបណ្តឹងនេះ គ.ជ.ប ចែកអង្គហេតុជាពីរ ទី១.ការចូលរួមជប់លៀងហូបនំបញ្ចុក និងថតរូប ទី២.ការបង្ហោះរូបភាពភ្ជាប់ជាមួយសារក្នុងគណនីបណ្តាញសង្គមហ្វេសបុក។ មូលហេតុដែល គ.ជ.ប លើកលែងការជាកពិន័យចំពោះឈ្មោះ **ម៉ាង ឈុន** និងឈ្មោះ **ពៅ តាំង** ព្រោះពួកគាត់មិនបានចូលរួមបង្ហោះនោះទេ ដោយឡែកឈ្មោះ **ជា ជីវ** ជាអ្នកផ្តើមគំនិត ចំណែកពីរនាក់ទៀតឈ្មោះ **ថោង សារឿន** និងឈ្មោះ **ត្រុយ គឹមសាំង** ជាអ្នកចូលរួមបង្ហោះ ហើយការជាកពិន័យនេះ គ.ជ.ប បានបន្ថយមកនៅត្រឹមកម្រិតអប្បបរមានៃការពិន័យតាមមាត្រា ១៤២ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។ ក្រៅពីនេះខ្ញុំមានឯកសារជាសារណាការពារចំនួន ០៤ទំព័រ ភ្ជាប់មកជាមួយ។ សូមឱ្យក្រុមប្រឹក្សាជំនុំជម្រះនៃក្រុមប្រឹក្សាធម្មនុញ្ញតម្កល់សេចក្តីសម្រេចលេខ ០០៩ ចុះថ្ងៃទី ០៨ ខែសីហា ឆ្នាំ២០១៨ របស់ គ.ជ.ប ទុកជាបានការពេញទាំងមូល។"

-នៅពេលសវនាការជំនុំជម្រះជាសាធារណៈឯកឧត្តម **មាន សទិ** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានថ្លែងថា ចំពោះអង្គហេតុ និង មូលដ្ឋាននៃការសម្រេចមានដូចក្នុងសារណាដែលបានផ្តល់ជូនក្រុមទី២ នៃក្រុមប្រឹក្សាធម្មនុញ្ញ និងបានបញ្ជាក់បន្ថែម៖

-មុនពេលកើតហេតុ គឺមានចលនាពីខាងក្រៅជំរុញឱ្យមាន "យុទ្ធនាការម្រាមដៃស្អាត យុទ្ធនាការដេកផ្ទះឈ្នះឯង" ដែលជាសកម្មភាពផ្ទុយនឹងច្បាប់ និងព្រះរាជសារព្រះករុណាព្រះមហាក្សត្រ និងបំបាត់ជំនឿទុកចិត្តលើគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

-ក្រោយមកទៀតមានការបំផុសចលនាគូសបំផ្លាញសន្លឹកឆ្នោត ដែលនាំឱ្យសន្លឹកឆ្នោតមិនបានការកើនឡើង ដែលមានចំនួនសរុបប្រហែល ៦០ម៉ឺនសន្លឹក។

-ចលនាប្រឆាំងច្បាប់ និងព្រះរាជសារនេះ និងចលនាបង្ហោះហ្វេសបុក ដែលកំពុងមានប្រជាប្រិយភាព គឺជាសកម្មភាពរួមគ្នាធ្វើឡើងក្នុងចេតនាបំផ្លាញការបោះឆ្នោត។

-ក្រុមប្រឹក្សាជំនុំជម្រះនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានសម្រេចលើកលែងការផាកពិន័យឈ្មោះ **ម៉ាង ឈុន** និងឈ្មោះ **ពៅ តាំង** បន្ថយការផាកពិន័យឈ្មោះ **ថោង សារឿន** និងឈ្មោះ **ក្រុយ គឹមសាំង** ពី១០លានរៀល មកត្រឹម ៥លានរៀល និងរក្សាការផាកពិន័យឈ្មោះ **ជា ជីវ** ចំនួន១០លានរៀលដដែល។

-សំណូមពរក្រុមប្រឹក្សាជំនុំជម្រះនៃក្រុមប្រឹក្សាធម្មនុញ្ញកម្ពុជាសេចក្តីសម្រេចលេខ ០០៩ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៨ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ទុកជាបានការ

-តាមការចុះស៊ើបអង្កេតរបស់មន្ត្រីជំនាញ នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ ភស្តុតាងដែលទទួលបាន មានដូចជារូបភាពបង្ហោះក្នុងគណនីបណ្តាញសង្គមហ្វេសបុកវ៉ីដេអូឃ្លីប ដែលភ្ជាប់ជាមួយសារគាំទ្រវ៉ីដេអូឃ្លីបរបស់លោក **សម រង្ស៊ី** ដែលបានអំពាវនាវឱ្យប្រជាពលរដ្ឋធ្វើពហិការមិនទៅចូលរួមបោះឆ្នោត នៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៨ ក្នុងយុទ្ធនាការម្រាមដៃស្អាត

ក្រោយពីបានស្តាប់ការឆ្លើយបំភ្លឺរបស់លោកមេធាវីដើមបណ្តឹង

ក្រោយពីបានស្តាប់ការឆ្លើយបំភ្លឺរបស់តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ក្រោយពីបានពិនិត្យពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

-យល់ឃើញថា ពាក្យបណ្តឹងរបស់ឈ្មោះ **ជា ជីវ** ឈ្មោះ **ថោង សារឿន** និងឈ្មោះ **ក្រុយ គឹមសាំង** ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៨ ដែលមានលោកមេធាវី **សំ សុគង់**

ជាអ្នកតំណាងដោយអាណាត្តិ ប្តឹងជំទាស់នឹងសេចក្តីសម្រេចលេខ ០០៩ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៨ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ស្ថិតក្នុងអំឡុងពេល ៧២ម៉ោង បន្ទាប់ពីកាលបរិច្ឆេទទទួលបានសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ យោងតាមមាត្រា ១៦៤ នៃច្បាប់ស្តីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងមាត្រា ២៦.៦ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ មាត្រា ២៧ ថ្មី មាត្រា ២៨ មាត្រា ៣១ និង មាត្រា ៣២ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដូច្នេះក្រុមប្រឹក្សាធម្មនុញ្ញ អាចទទួលយកបណ្តឹងនេះមកពិនិត្យបាន

-យល់ឃើញថា លោក **សម រង្សុ** និង អតីតថ្នាក់ដឹកនាំអតីតគណបក្សសង្គ្រោះជាតិ បានអំពាវនាវពីក្រៅប្រទេស ឱ្យប្រជាពលរដ្ឋធ្វើពហិការមិនទៅចូលរួមការបោះឆ្នោតថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៨ ដោយចោទប្រកាន់ថាការបោះឆ្នោតថ្ងៃខាងមុខគឺជាការបោះឆ្នោតក្លែងក្លាយ។ ក្រុមមេដឹកនាំអតីតគណបក្សសង្គ្រោះជាតិចាប់ផ្តើមបំផុសអំពីយុទ្ធនាការម្រាមដៃស្អាត តាមរយៈមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ ដែលមានលក្ខណៈជាប្រព័ន្ធសម្រាប់សាធារណជន ក្នុងគោលបំណងបំផុសប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតមិនឱ្យទៅបោះឆ្នោត និង ធ្វើឱ្យមានការកាន់ច្រឡំនាំឱ្យបាត់ទំនុកចិត្តលើការបោះឆ្នោត។ ផែនការបំផុសអំពីយុទ្ធនាការម្រាមដៃស្អាត បានរីករាលដាលកាន់តែធំទៅៗ តាំងពីក្នុងរាជធានី ខេត្ត រហូតដល់ឃុំ សង្កាត់ទូទាំងប្រទេស។

អង្គហេតុខាងលើនេះត្រូវបានបញ្ជាក់ដោយភស្តុតាង ដែលទទួលបានពីការចុះស៊ើបអង្កេតរបស់មន្ត្រីជំនាញនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ មានរូបភាពបង្ហោះក្នុងគណនីបណ្តាញសង្គមហ្វេកបុក វីដេអូយ្លីប ដែលភ្ជាប់ជាមួយសារគាំទ្រវីដេអូយ្លីបរបស់លោក **សមរង្សុ** ដែលបានអំពាវនាវឱ្យប្រជាពលរដ្ឋធ្វើពហិការមិនទៅចូលរួមបោះឆ្នោតនៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៨ ក្នុងយុទ្ធនាការម្រាមដៃស្អាត

-យល់ឃើញថា ការជួបជុំ ការថតរូបជុំគ្នាដែលបានលើកម្រាមដៃចង្អុលទៅលើមេយ និងការបង្ហោះរូបភាព និងសារ តាមបណ្តាញសង្គមហ្វេសបុកជាការប្រើប្រាស់សេរីភាពក្នុងការបញ្ចេញមតិដោយផ្អែកលើខ្លឹមសារមាត្រា១៩ នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងមាត្រា៤១ និង មាត្រា៤២ នៃរដ្ឋធម្មនុញ្ញ គឺជាការ

បកស្រាយដោយផ្អែកលើផ្នែកមួយនៃបទប្បញ្ញត្តិនៃមាត្រានេះតែប៉ុណ្ណោះ។ ប៉ុន្តែតាមបទប្បញ្ញត្តិនេះនៅពេលដែលពលរដ្ឋប្រើប្រាស់សិទ្ធិត្រូវភ្ជាប់នឹងករណីយកិច្ច ដែលត្រូវគោរពសិទ្ធិរបស់អ្នកដទៃ ការការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ទំនៀមទំលាប់ល្អរបស់សង្គម សន្តិសុខជាតិ លទ្ធិប្រជាធិបតេយ្យជាអាទិ៍... ដែលត្រូវបានការពារដោយច្បាប់

-យល់ឃើញថា ការជួបជុំនៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៨ ឈ្មោះ **ជា ជីវ** ឈ្មោះ **ថោង សារឿន** និងឈ្មោះ **ត្រុយ គឹមសាំង** បានជួបជុំគ្នា និងថតរូបបង្ហាញចង្អុលដៃគ្មានស្នាមប្រឡាក់រួចបង្ហោះរូបថតទាំងនោះនៅលើបណ្តាញទំនាក់ទំនងសង្គមហ្វេសបុក ដោយភ្ជាប់ជាមួយនឹងការប្រើពាក្ស "*ម្រាមដៃខ្ញុំពិតជាស្អាត ម្រាមដៃខ្ញុំត្រូវតែស្អាត បើគ្មានគណបក្សសង្គ្រោះជាតិ ម្រាមដៃស្អាត ចិត្តជ្រះថ្លា មិនលក់មនសិការ និងម្រាមដៃយើងខ្ញុំពិតជាស្អាតណាស់...*" ប្រាកដមែន។ រូបភាពម្រាមដៃស្អាត និងសារទាំងនេះគឺជានិមិត្តសញ្ញានៃយុទ្ធនាការម្រាមដៃស្អាត ដែលបានបង្កើតឡើងក្នុងគោលបំណងរារាំងពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតមិនឱ្យទៅបោះឆ្នោត និងធ្វើឱ្យមានការកាន់ច្រឡំនាំឱ្យបាត់ទំនុកចិត្តលើការបោះឆ្នោត

-យល់ឃើញថា សកម្មភាពដែលបានប្រព្រឹត្តដោយឈ្មោះ**ជា ជីវ** ឈ្មោះ **ថោង សារឿន** និងឈ្មោះ **ត្រុយ គឹមសាំង** ធ្វើឡើងដោយចេតនា

-យល់ឃើញថា ការមិនយល់ដឹងអំពីច្បាប់របស់ពលរដ្ឋ ធ្វើឱ្យពលរដ្ឋនោះរួចផុតពីការទទួលខុសត្រូវចំពោះមុខច្បាប់ គឺជាការកាន់ច្រឡំ ដោយហេតុថាជាគោលការណ៍នៃការអនុវត្តច្បាប់ ការមិនយល់អំពីច្បាប់ មិនអាចយកមកធ្វើជាយុត្តិកម្ម ឬ ធ្វើឱ្យបុគ្គលនោះរួចផុតពីការទទួលខុសត្រូវចំពោះមុខច្បាប់ឡើយ

-យល់ឃើញថា ការដែលលើកឡើងថា អ្នកប្តឹងត្រូវតែមានប្រយោជន៍ក្នុងការប្តឹង គឺជាការយល់ច្រឡំ ដោយហេតុថាបណ្តឹងខ្លះត្រូវធ្វើដោយបុគ្គលដែលឆ្លើយតបតាមលក្ខខណ្ឌនៃច្បាប់ និងមានប្រយោជន៍ក្នុងការប្តឹង ប៉ុន្តែបណ្តឹងទាមទារឱ្យអនុវត្តតាមជំពូកទី១០ (ទោសប្បញ្ញត្តិ) នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ផលប្រយោជន៍របស់អ្នកប្តឹង មិនមែនជាលក្ខខណ្ឌនៃប្រធានបណ្តឹងឡើយ លើកលែងតែការអនុវត្តមាត្រា ១៦៤ នៃច្បាប់នេះ

-យល់ឃើញថា ការលើកឡើងថាសកម្មភាពរារាំង គឺជាអំពើហិង្សា រារាំងប្រជាពលរដ្ឋ នៅពេលដែលប្រជាពលរដ្ឋកំពុងតម្រង់ជួរទៅបោះឆ្នោត គឺជាការភាន់ច្រឡំក្នុងការ បកស្រាយខ្លឹមសារនៃមាត្រា ១៤២ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាង រាស្ត្រ។ តាមអត្ថន័យនៃមាត្រា ១៤២ នៃច្បាប់នេះ អំពើរារាំងអាចស្តែងឡើងតាម គ្រប់រូបភាព គ្រប់មធ្យោបាយក្នុងគោលបំណងហាមឃាត់ ទប់ចិត្តមិនឱ្យពលរដ្ឋ បង្ហាញឆន្ទៈរបស់ខ្លួនបាន ជាពិសេសក្នុងការអនុវត្តសិទ្ធិប្រជាធិបតេយ្យដែលស្តែង ឡើងតាមរយៈការបោះឆ្នោត ហើយសកម្មភាពនេះមិនទាមទារឱ្យត្រូវតែកើតឡើង នៅក្នុងអំឡុងពេលដែលពលរដ្ឋតម្រង់ជួរដើម្បីបោះឆ្នោតឡើយ ពោលគឺសកម្មភាព អាចស្តែងឡើងនៅគ្រប់ដំណាក់កាលនៃការបោះឆ្នោត

-យល់ឃើញថា សិទ្ធិបោះឆ្នោតមានតម្លៃធម្មនុញ្ញ ដូចមានចែងក្នុងមាត្រា ៣៤ ថ្មី(មួយ) នៃរដ្ឋធម្មនុញ្ញ "ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិបោះឆ្នោត និងអាចឈរឈ្មោះ ឱ្យគេបោះឆ្នោត។..."

-យល់ឃើញថា សិទ្ធិបោះឆ្នោតជាគ្រឹះដ៏សំខាន់នៃដំណើរការប្រជាធិបតេយ្យ និងសេរី ភាពរបស់បុគ្គល ដែលបានគាំពារដោយមាត្រា ១៤២ នៃច្បាប់ស្តីពីការបោះឆ្នោត ជ្រើសតាំងតំណាងរាស្ត្រ

-យល់ឃើញថា រាល់សកម្មភាពដែលស្តែងឡើងតាមគ្រប់មធ្យោបាយដែលមានចេតនា មិនឱ្យប្រជាពលរដ្ឋ ដែលមានសិទ្ធិបោះឆ្នោតទៅបោះឆ្នោត ជាអំពើរារាំងស្របតាម អត្ថន័យនៃមាត្រា ១៤២ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

-យល់ឃើញថា អត្ថន័យនៃមាត្រា១៤២ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាង រាស្ត្រ "អំពើរារាំងមិនឱ្យប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតមិនឱ្យទៅបោះឆ្នោត និងធ្វើឱ្យមានការភាន់ច្រឡំនាំឱ្យបាត់ទំនុកចិត្តលើការបោះឆ្នោត ទាមទារឱ្យមានតែ អំពើ ទោះបីតាមមធ្យោបាយណាមួយ ក្រោមរូបភាពអ្វីមួយដែលមិនត្រឹមត្រូវ ក្នុង គោលបំណងរារាំង ធ្វើឱ្យមានការភាន់ច្រឡំនាំឱ្យបាត់ជំនឿទុកចិត្តលើការបោះឆ្នោត" គឺឆ្លើយតបគ្រប់គ្រាន់តាមសញ្ញាគតិយុត្តដែលចែងក្នុងមាត្រានេះ ដោយមិនតម្រូវឱ្យ កើតនូវព្យសនកម្ម ដូចអ្វីដែលជនប្រព្រឹត្តចង់បាននោះឡើយ

-យល់ឃើញថា សកម្មភាពរបស់ឈ្មោះ **ជា ជីវ** ឈ្មោះ **ថោង សារឿន** និងឈ្មោះ **ក្រុយ គឹមសាំង** ដែលបានប្រព្រឹត្តដូចខាងលើ គឺសកម្មភាពដែលត្រូវបានហាមឃាត់ និងត្រូវទទួលទណ្ឌកម្មតាមមាត្រា ១៤២ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

-យល់ឃើញថា ពាក្យបណ្តឹងរបស់ឈ្មោះ **ជា ជីវ** ឈ្មោះ **ថោង សារឿន** និងឈ្មោះ **ក្រុយ គឹមសាំង** ដែលមានលោកមេធាវី **សំ សុគង់** ជាអ្នកតំណាងដោយអាណត្តិ ប្តឹងជំទាស់នឹងសេចក្តីសម្រេចលេខ ០០៩ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៨ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងសេចក្តីថ្លែងការណ៍របស់លោកមេធាវី **សំ សុគង់** ពុំមានភស្តុតាងដែលបញ្ជាក់អំពីមូលហេតុនៃការទាមទារដែលនាំឱ្យមានការលុបចោលសេចក្តីសម្រេចលេខ ០០៩ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៨ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឡើយ

-យល់ឃើញថា ការជួបជុំ ការថតរូបលើកម្រាមដៃចង្អុលទៅលើមេយ និងការបង្ហោះតាមបណ្តាញសង្គមហ្វេសបុកដោយដាក់ចំណងជើងថា "ម្រាមដៃខ្ញុំត្រូវតែស្អាត បើគ្មានគណបក្សសង្គ្រោះជាតិ ម្រាមដៃស្អាត ចិត្តជ្រះថ្លា មិនលក់មនសិការ និងម្រាមដៃយើងខ្ញុំពិតជាស្អាតណាស់..." គឺកើតឡើងនៅលំនៅដ្ឋានរបស់ឈ្មោះ **ជា ជីវ** ដែលជាការផ្ទួចផ្ដើមគំនិតរបស់ឈ្មោះ **ជា ជីវ** នេះ

-យល់ឃើញថា សេចក្តីសម្រេចលេខ ០០៩ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៨ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានមូលដ្ឋានគតិយុត្តត្រឹមត្រូវ

សម្រេច

មាត្រា ១៖ ទទួលពាក្យបណ្តឹងរបស់ឈ្មោះ **ជា ជីវ** ឈ្មោះ **ថោង សារឿន** និងឈ្មោះ **ក្រុយ គឹមសាំង** ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៨ ដែលមានលោកមេធាវី **សំ សុគង់** ជាអ្នកតំណាងដោយអាណត្តិ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់។

មាត្រា ២៖ កម្ពស់សេចក្តីសម្រេចលេខ ០០៩ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៨ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ទុកជាបានការ។

មាត្រា ៣. សេចក្តីសម្រេចនេះ ប្រកាសនាសវនាការជាសាធារណៈ នៅរាជធានីភ្នំពេញ ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៨ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងត្រូវចុះផ្សាយក្នុងរាជកិច្ច។

ថ្ងៃពុធ ៤កើត ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៨

ជ.ក្រុមប្រឹក្សាធម្មនុញ្ញ និងជាក្រុមប្រឹក្សាជំនុំជម្រះ

ប្រធាន

អ៊ីម ឈុនលឹម

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ
ចូល លេខ 354/005/2018
ថ្ងៃ 10 ខែ 14 ឆ្នាំ 2018

ពាក្យបណ្តឹង

ខ្ញុំបាទ មេធាវី **សំ សុគន្ធ** អត្តលេខ៣២១ ជាមេធាវី នៃក្រុមហ៊ុនមេធាវី **ប៊ីប៊ីស៊ី** និងជាសមាជិក គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា អស័យដ្ឋានការិយាល័យផ្ទះលេខ១៤CEo ផ្លូវលេខ៣៨៤ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ ជាមេធាវីតំណាងអាណត្តិឲ្យអាណត្តិទាយកៈ

១. **ជា ជីវ** ភេទប្រុស កើតនៅឆ្នាំ១៩៨១ អស័យដ្ឋានរស់នៅផ្ទះលេខ៥០២ ផ្លូវលេខ/ក្រុម២ ភូមិជំនីក សង្កាត់-ឃុំអន្លង់រ៉ាល ក្រុង/ស្រុកបាត់ដំបង រាជធានី-ខេត្តបាត់ដំបង ។

២. **ថោង សារឿន** ភេទប្រុស កើតនៅឆ្នាំ១៩៦៧ អស័យដ្ឋានរស់នៅផ្ទះលេខ១៤០ ផ្លូវលេខ/ក្រុម ៨ ភូមិគាស់ក្រឡសង្កាត់-ឃុំគាស់ក្រឡ ខណ្ឌ-ស្រុកគាស់ក្រឡ រាជធានី-ខេត្តបាត់ដំបង ។

៣.**គ្រុយ គឹមសាំង** ភេទប្រុស កើតនៅឆ្នាំ១៩៧៤អស័យដ្ឋានរស់នៅផ្ទះលេខ១៦២ ផ្លូវលេខ១ ភូមិដូង សង្កាត់-ឃុំបឹងរ៉ាំង ខណ្ឌ-ស្រុកកំរៀង រាជធានី-ខេត្តបាត់ដំបង

សូមគោរពជូន
ឯកឧត្តម ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

កម្មវត្ថុៈ សុំប្តឹងជំទាស់នឹងសេចក្តីសម្រេចលេខ: ០០៩ **ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៨** របស់ គណកម្មាធិការជាតិរៀបចំការបោះឆ្នោត

យោងៈ -សេចក្តីសម្រេចលេខ: ០០៩ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៨ របស់ គជប
-សេចក្តីសម្រេចលេខ: ០០១ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៨ របស់ គខប.បប
-លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៨

កាលពីថ្ងៃទី០៨ ខែ០៨ ឆ្នាំ២០១៨ ក្រុមប្រឹក្សាជំនុំជម្រះនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានបើកសវនាការលើបណ្តឹងជំទាស់នឹងសេចក្តីសម្រេចលេខ: ០០១ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៨ របស់ គណៈកម្មការរៀបចំការបោះឆ្នោត ខេត្តបាត់ដំបង និង ក្រោយពីបានបើកសវនាការចប់ ប្រធានក្រុមប្រឹក្សាជំនុំជម្រះបានប្រកាសសេចក្តីសម្រេចលេខ: ០០៩ ចុះថ្ងៃទី០៨ ខែ០៨ ឆ្នាំ២០១៨ របស់ គជប ដោយបានសម្រេចដម្កល់សេចក្តីសម្រេចលេខ: ០០១ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៨ របស់គខប.បប ចំពោះកូនក្តីខ្ញុំបាទ លោក ជា ជីវ ប៉ុន្តែកែប្រែចំណុចទី៣ ចាប់ពីត្រែទី២ ទៅ ដោយសម្រេចឡើងវិញៈ ១-ផាកពិន័យជាប្រាក់ចំនួន ៥.០០០.០០០ (ប្រាំលាន) រៀល ក្នុងម្នាក់ៗ ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះឈ្មោះ ថោង សារឿន និង ឈ្មោះ គ្រុយ គឹមសាំង។

ដោយសារកូនក្តីខ្ញុំបាទទាំង ០៣នាក់ខាងលើ យល់ឃើញថា សេចក្តីសម្រេចលេខ: ០០៩ **ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៨** របស់ គណកម្មាធិការជាតិរៀបចំការបោះឆ្នោត មិនបានផ្តល់យុត្តិធម៌ដល់ពួកខ្លួន ទើប

កូនក្តីទាំង ០៣នាក់ខាងលើ បានធ្វើលិខិតតំណាងដោយអាណត្តិជូនមេធាវីដើម្បីមានសិទ្ធិនិងមានអំណាចក្នុងការធ្វើបណ្តឹងជំទាស់ទៅក្រុមប្រឹក្សាធម្មនុញ្ញ និងធ្វើសកម្មភាពតំណាងឲ្យខ្លួននៅក្រុមប្រឹក្សាធម្មនុញ្ញ។

១.អង្គហេតុ

- នៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៨ កូនក្តីខ្ញុំបាទទាំង ៥នាក់ និងប្រជាពលរដ្ឋមួយចំនួនបានមកជួបជុំគ្នា នៅផ្ទះ លោក ជា ជីវ គោលបំណងជួបជុំគ្នាពិសារនំបញ្ចុក ដែលគ្រួសារលោក ជា ជីវ មានបំណងដង្ហែទានវស្សាទៅវត្ត។
- ក្រោយពីពិសារនំបញ្ចុករួចកូនក្តីខ្ញុំបាទ និងប្រជាពលរដ្ឋមួយចំនួនទៀតបានថតរូបជុំគ្នា ដោយបានលើកម្រាមដៃចង្អុលទៅលើមេឃ ដើម្បីថតទុកជាអនុស្សាវរីយ៍ និងបង្ហាញពីឆន្ទៈផ្ទាល់ខ្លួនថាខ្លួនប្រើប្រាស់សិទ្ធិពលរដ្ឋនិងមិនទៅបោះឆ្នោតនៅថ្ងៃបោះឆ្នោតជាតិ ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៨ ខាងមុខ។
- ក្រោយមកកូនក្តីខ្ញុំបាទលោក ជា ជីវ, លោក ថោង សារឿន និង លោក គ្រុយ គឹមសាំង បានយករូបភាពមកបង្ហោះតាមបណ្តាញសង្គមហ្វេសបុកដោយដាក់ចំណងជើងថា " ម្រាមដៃខ្ញុំត្រូវតែស្អាត បើគ្មានគណបក្សសង្គ្រោះជាតិ ម្រាមដៃស្អាត ចិត្តជ្រះថ្លា មិនលក់មនសិកា និងម្រាមដៃយើងខ្ញុំពិតជាស្អាតណាស់..."

២.អង្គច្បាប់

- មាត្រា ៤១ និង មាត្រា៤២ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- មាត្រា ១៤២ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- មាត្រា ៥ នៃក្រមព្រហ្មទណ្ឌ

៣.ភស្តុតាងបញ្ជាក់អំពីមូលហេតុ

មេធាវីតំណាងអាណត្តិយល់ឃើញថា៖

- ការយល់ឃើញ ក្នុងទំព័រទី៥ និង ទំព័រទី៦ នៃ សេចក្តីសម្រេចរបស់ គខប.បប និងការយល់ឃើញ ក្នុងទំព័រទី៤ នៃសេចក្តីសម្រេចរបស់ គជប មិនទាន់ត្រឹមត្រូវ និងមានការភាន់ច្រឡំទាំងអង្គហេតុ និង អង្គច្បាប់ នៃមាត្រា ១៤២ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងបានយកទិន្នន័យនៃចំនួនអ្នកទៅបោះឆ្នោត និង ទិន្នន័យ នៃសន្លឹកឆ្នោតមិនបានការគាលពីបោះឆ្នោតជ្រើសតាំង ឃុំសង្កាត់ ឆ្នាំ២០១៧ ទៅប្រៀបធៀបទិន្នន័យចំនួនអ្នកទៅបោះឆ្នោតជាតិឆ្នាំ២០១៨។
- ការជួបជុំគ្នារវាងពលរដ្ឋនិងពលរដ្ឋ និងបង្ហោះរូបភាពជាមួយនឹងសារមិនប៉ះពាល់សិទ្ធិអ្នកដ៏ទៃ គឺ ជាការអនុវត្តសិទ្ធ ពលរដ្ឋ និង សិទ្ធនយោបាយ ដែលធានាដោយមាត្រា៣១,មាត្រា៤១ និងមាត្រា៤២ នៃរដ្ឋធម្មនុញ្ញ ដោយហេតុថា ការថតរូបលើកម្រាមដៃគ្មានស្នាមប្រលាក់ មិនមែនជាសកម្មភាពខុសច្បាប់ទេ គឺជាការថតរូបជុំគ្នា និងថតទុកជាអនុស្សាវរីយ៍ នៅពេលជួបជុំគ្នាហូបនំបញ្ចុក និងគោលបំណងខ្លួនឯង និងមិនទៅបោះឆ្នោតនៅថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៨ ដោយសារខ្លួនមិនពេញចិត្តគណបក្សនយោបាយណាមួយ ឬ គណបក្សនយោបាយដែលខ្លួនស្រលាញ់ត្រូវបានរំលាយ ឬ មិនបានចូលរួម។
- ទោះជាមានការបង្ហោះរូបភាពលើកម្រាមដៃឡើងលើមេឃ និងបានដាក់ចំណងជើងថា " ម្រាមដៃខ្ញុំត្រូវតែស្អាត បើគ្មានគណបក្សសង្គ្រោះជាតិ ម្រាមដៃស្អាត ចិត្តជ្រះថ្លា មិនលក់មនសិកា និង

ម្រាមដៃយើងខ្ញុំពិតជាស្អាតណាស់...”ខ្ញុំបាទជាមេធាវីតំណាងដោយអាណត្តិឲ្យកូនក្តីទាំង០៥រូបខាងលើ មិនឃើញមានខ្ជឹមសារ ឬពាក្យណាមួយ ជាការអំពាវនាវ ឬរារាំងមិនឲ្យប្រជាពលរដ្ឋមិនទៅបោះឆ្នោតនោះទេ ដោយសារ អត្ថន័យនៅក្នុងសារនេះ កូនក្តីខ្ញុំបាទ បាននិយាយខ្លួនឯងជាអ្នកសរសេរ និងការប្រើប្រាស់សិទ្ធិខ្លួនឯង ហើយក្នុងស្មារតីនៃមាត្រា១៤២ នៃ ខ្ជឹមសាររារាំងមានន័យថា ជាអំពើសកម្ម ទៅលើអ្នកណាផ្សេងក្រៅពីខ្លួនឯង ។

- ការយល់ឃើញរបស់ គខប.បប និង ការយល់ឃើញរបស់ គជប ដោយបានយកអង្គហេតុ របស់ឯកឧត្តម សម រង្ស៊ី និង យកអង្គហេតុរបស់ លោកមេធាវី ជួង ជូងី មកភ្ជាប់ជាមួយអង្គហេតុកូនក្តីខ្ញុំបាទនេះ គឺ មិនទាន់ត្រឹមត្រូវ និងមានការកាន់ច្រឡំអង្គហេតុទាំងស្រុង ដោយសារ អង្គហេតុកូនក្តីខ្ញុំបាទ បានប្រើសិទ្ធិពលរដ្ឋ ក្នុងការចូលរួមក្នុងសកម្មភាពនយោបាយ ដែលធានាដោយមាត្រា ៤១ និងមាត្រា៤២ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា និង មិនល្មើសនឹងមាត្រា ១៤២ នោះទេ ដោយហេតុថា នៅក្នុងមាត្រា១៤២ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ បានចែងក្នុង វយខណ្ឌទី៥ " ការារាំងប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោត មិនឲ្យទៅបោះឆ្នោត”ក្នុងស្មារតីនៃមាត្រានេះ សំដៅដល់សកម្មភាពសកម្មណាមួយ នៅក្នុងអំឡុងពេលបោះឆ្នោត ដោយសារការគម្រាមកំហែង ការប្រើហឹង្សា និង ការារាំងណាមួយនៅពេលបោះឆ្នោត។
- ការយល់ឃើញថា ផ្អែកតាមមាត្រា ៤១ នៃរដ្ឋធម្មនុញ្ញ ត្រង់ទំព័រទី៦ នៃសេចក្តីសម្រេចរបស់ គខប.បប ការប្រើប្រាស់សិទ្ធិរបស់កូនក្តីខ្ញុំបាទ មិនបានប៉ះពាល់ដល់សិទ្ធិរបស់អ្នកដទៃនោះទេ កូនក្តីខ្ញុំបានបង្ហោះរូបថត កាលពីថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៨ និងការបោះឆ្នោតនៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៨ សកម្មភាពនេះមិនល្មើសនិងមាត្រា១៤២ ទេ។
- តាមការប្រកាសក្រៅផ្លូវការរបស់គណកម្មាធិការរៀបចំការបោះឆ្នោត (គជប) បានបង្ហាញថា អ្នកទៅបោះឆ្នោត ដល់ទៅជា ៨២.៨៩ ។ ។
- នៅក្នុងរឿននេះ ខ្ញុំបាទមិនមានកស្តុតាងជាសាក្សីទេ តែខ្ញុំបាទមានកស្តុតាងឯកសាររូបថត។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ **ឯកឧត្តមប្រធាន** មេត្តាពិនិត្យ និងសម្រេច។

សូម **ឯកឧត្តមប្រធាន** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

ធ្វើនៅថ្ងៃទី០៩ ខែ០៨ ឆ្នាំ២០១៨
មេធាវីតំណាងដោយអាណត្តិ

AVOCAT
ATTORNEY
AT LAW
KINGDOM OF CAMBODIA

មេធាវី.ស៊ីដូ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៧៧.៤៨.អស.ក្រ.ត

អនុក្រឹត្យ
ស្តីពីការជូនមេដាយមុនីសារាត់ណ្ឌ
រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស

សម្រេច

មាត្រា១.. បំពាក់ **មេដាយមុនីសារាត់ណ្ឌ** តាមលំដាប់ថ្នាក់ ប្រគេនធិងជូនសប្បុរសជន ចំនួន ៩ រូប ដែលមានស្នាព្រះហស្តនិងស្នាដៃល្អក្នុងការចូលរួមជួយកសាងសមិទ្ធផលនានា នៅឃុំចុងអូង ស្រុកបារាយណ៍ ខេត្តកំពង់ធំ កន្លងមក ដូចមានរាយព្រះនាមនិងនាមខាងក្រោម ៖

ក-មេដាយមុនីសារាត់ណ្ឌ ថ្នាក់ ធិបឌិន្ត

១-ព្រះតេជគុណ	**សេត**	**រិទ្ធិ**	ព្រះចៅអធិការវត្តដំណាក់ថ្មីបារមីមានរិទ្ធិ
២-ព្រះតេជគុណ	**ភ្ជឿន**	**ចន្ធា**	គង់នៅខេត្តកំពង់ចាម

ខ-មេដាយមុនីសារាត់ណ្ឌ ថ្នាក់ សេនា

១-ព្រះតេជគុណ	**ឆ្លូង**	**សុម៉ាលី**	គង់នៅខេត្តកំពង់ធំ
២-លោក	**ចោង**	**សារលួន**	សប្បុរសជននៅខេត្តកំពង់ធំ
៣-លោក	**ជួង**	**ចំន្ទជារ៉ា**	សប្បុរសជននៅខេត្តកំពង់ធំ
៤-លោក	**ហាង្ស**	**ឥន្ធិកា**	សប្បុរសជននៅខេត្តកំពង់ធំ

គ-មេដាយមុនីសារាត់ណ្ឌ ថ្នាក់ អស្សបូទ្ធិ

១-លោក	**ត្រីស**	**ប៊ុនឈ្យើន**	សប្បុរសជននៅខេត្តកំពង់ធំ
២-លោក	**ឆាន**	**ធន**	សប្បុរសជននៅខេត្តកំពង់ធំ
៣-លោក	**លុយ**	**ធីន**	សប្បុរសជននៅខេត្តកំពង់ធំ

មាត្រា២.. រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស អភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃសុក្រ ៥ រោច ខែទន្ទិ ១ ១ ១

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៧២៤៩ អនក្រ.តត

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ
រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស

សម្រេច

មាត្រា១.. បំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេននិងជូនសប្បុរសជន ចំនួន១០រូប ដែលបានបរិច្ចាគបច្ច័យនិងថវិកា ចូលរួមជួយកសាងសមិទ្ធផលនានា នៅឃុំចុងអូង ស្រុកបារាយណ៍ ខេត្តកំពង់ធំ កន្លងមក ដូចមានរាយព្រះនាមនិងនាមខាងក្រោម ៖

១-ព្រះតេជគុណ	ញ៉ឹក	ហុង	គង់នៅខេត្តកំពង់ធំ	បច្ច័យចំនួន ១១.៥០០ ដុល្លារ
២-លោក	ហ៊ាន់	នាយ	សប្បុរសជននៅខេត្តកំពង់ធំ	ថវិកាចំនួន ១១.៣៥០ ដុល្លារ
៣-លោក	ម្យ៉ាង	ណារ	សប្បុរសជននៅខេត្តកំពង់ធំ	ថវិកាចំនួន ១១.២៤០ ដុល្លារ
៤-លោក	ទុត	ស៊ុន	សប្បុរសជននៅខេត្តកំពង់ធំ	ថវិកាចំនួន ១១.១១៥ ដុល្លារ
៥-លោក	ហ្ស៊ីម	សុង	សប្បុរសជននៅខេត្តកំពង់ធំ	ថវិកាចំនួន ១១.០៩០ ដុល្លារ
៦-លោក	ង៉ែ	ហាន	សប្បុរសជននៅខេត្តកំពង់ធំ	ថវិកាចំនួន ១០.១៥០ ដុល្លារ
៧-លោក	ភ៉ីម	ឆុន	សប្បុរសជននៅខេត្តកំពង់ធំ	ថវិកាចំនួន ១០.១៤០ ដុល្លារ
៨-លោក	ឃ្លាំង	ឃ្យ៉ាង	សប្បុរសជននៅខេត្តកំពង់ធំ	ថវិកាចំនួន ១០.១៣០ ដុល្លារ
៩-លោក	នង	ជីន	សប្បុរសជននៅខេត្តកំពង់ធំ	ថវិកាចំនួន ១១.១១៥ ដុល្លារ
១០-លោក	ញ៉ៃ	ង៉ែន	សប្បុរសជននៅខេត្តកំពង់ធំ	ថវិកាចំនួន ១១.០១៥ ដុល្លារ

មាត្រា២.. រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស អភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃសុក្រ ៨ កើត ខែ ទុតិយាសាឍ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស.២៥៦២
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១៨

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-រដ្ឋមន្ត្រី១ និងមន្ត្រី២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ...៧៤៥០...អនក្រ.ត.ត

អនុក្រឹត្យ
ស្តីពីការជូនមេដាយសហមេត្រី
រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់ គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១..បំពាក់ **មេដាយសហមេត្រី** តាមលំដាប់ថ្នាក់ ជូនកងទ័ពការពារព្រំដែន និងនគរបាលខេត្តគៀនយ៉ាង នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ចំនួន១៣រូប ដែលមានស្នាដៃល្អក្នុងកិច្ចសហប្រតិបត្តិការរក្សាសន្តិសុខ សណ្តាប់ធ្នាប់ និងសុវត្ថិភាពសង្គម តាមខ្សែបន្ទាត់ព្រំដែន រវាងប្រទេសទាំងពីរ ដូចមានរាយនាមខាងក្រោម៖

ក-មេដាយសហមេត្រី ថ្នាក់ ធិបឌិន្ត

១- ឧត្តមសេនីយ៍ត្រី	BUI TUYET MINH	នាយកមន្ទីរនគរបាល
២- វរសេនីយ៍ឯក	DANG MINH SANG	នាយករងមន្ទីរនគរបាល
៣- វរសេនីយ៍ឯក	NGUYEN VAN TUNG	នាយករងមន្ទីរនគរបាល
៤- វរសេនីយ៍ឯក	HO TU DIEN	មេបញ្ជាការកងទ័ពការពារព្រំដែន
៥- វរសេនីយ៍ឯក	DANG VANTHONG	មេបញ្ជាការនយោបាយ នៃកងទ័ពការពារព្រំដែន

ខ-មេដាយសហមេត្រី ថ្នាក់ សេនា

១- វរសេនីយ៍ឯក	NGUYEN THANH PHONG	នាយការិយាល័យ
២- វរសេនីយ៍ឯក	TRAN QUOE LAP	មេបញ្ជាការរង
៣- វរសេនីយ៍ឯក	VO VAN HOA	នាយការិយាល័យ
៤- វរសេនីយ៍ឯកបម្រុង	BUN THANH TU	នាយការិយាល័យ

៥- វរសេនីយ៍ឯកបម្រុង	LE DUNGSY	អនុប្រធានសេនាធិការ

ក-មេដាយសហាមេត្រី ថ្នាក់ អស្សឫទ្ធិ

១- វរសេនីយ៍ទោ	DANH NGOC SANG	ប្រធានគណៈកម្មការប្រជាចលនា
២- អនុសេនីយ៍ឯក	PHAM THI THUY HANG	នាយកផ្នែក
៣- អនុសេនីយ៍ឯក	NGUYEN TIEN VINH	ប្រធានក្រុមឃោសនាវប្បធម៌

មាត្រា២. រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ៥ រោចខែ ទុតិយាសាឍ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ២០១៨
នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការវាំងរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៧៥១...អនក្រ.ត

អនុក្រឹត្យ
ស្តីពីការជូនមេដាយមុនីសារាត់ណ្ឌ
រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

សម្រេច

មាត្រា១. បំពាក់ **មេដាយមុនីសារាត់ណ្ឌ** តាមលំដាប់ថ្នាក់ ប្រគេនទៅជូនសប្បុរសជន ចំនួន២២រូប ដែលមានស្នាព្រះហស្ត និងស្នាដៃល្អ ក្នុងការចូលរួមជួយកសាងសមិទ្ធផលនានា នៅវត្តមង្គលបូរី ហៅ វត្តមង់ ឃុំមង់រៀវ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ កន្លងមក ដូចមានរាយព្រះនាម និងនាមខាងក្រោម ៖

ក-មេដាយមុនីសារាត់ណ្ឌ ថ្នាក់ ធិបឌិន្ទ

១-ភិក្ខុវិបុលត្ថេរ	ចេង	ប៉ែចគ្រី	ព្រះគ្រូចៅអធិការវត្តមង្គលបូរី
២-លោក	**សៀ**	**ពិសិដ្ឋ**	សប្បុរសជន
៣-លោក	**សុខ**	**សាម**	សប្បុរសជន
៤-លោក	**លីម**	**ស៊ុនណាង**	សប្បុរសជន
៥-អ្នកស្រី	**គីម**	**លីន**	សប្បុរសជន
៦-អ្នកស្រី	**ម៉ាក់**	**អែលីម**	សប្បុរសជន
៧-អ្នកស្រី	**លីម**	**ស៊ាងលី**	សប្បុរសជន

ខ-មេដាយមុនីសារាត់ណ្ឌ ថ្នាក់ សេនា

១-លោក	**អ៊ីន**	**ថៃហ្ស**	សប្បុរសជន
២-អ្នកស្រី	**យន**	**ស៊ីផុនយី**	សប្បុរសជន
៣-ឧបាសក	**ចេង**	**លី**	សប្បុរសជន

៤-លោក	ហ៊ុ	សំអាត	សប្បុរសជន
៥-លោក	អ៊ីង	ហារ៉ាសែ	សប្បុរសជន
៦-លោក	សាំង	ទិត្យា	សប្បុរសជន
គ-មេជាយមុនីសាវតំណូ ថ្នាក់ អសប្បុរិ			
១-អ្នកស្រី	លី	ហួយណាង	សប្បុរសជន
២-លោក	ថៃ	ជ្រៀង	សប្បុរសជន
៣-អ្នកស្រី	ផល	សំណាង	សប្បុរសជន
៤-លោក	ជ៉ាល់	រ៉ែន	សប្បុរសជន
៥-លោក	ម៉ី	សូលីណា	សប្បុរសជន
៦-លោក	សាំង	ហ្ជូស្ត្រ៊ីន	សប្បុរសជន
៧-លោក	ឈិត	ចេរ៉ាវ	សប្បុរសជន
៨-លោក	ត្រាំ	ណារ៉ាន់	សប្បុរសជន
៩-លោក	ឆុយ	សេង	ជំទប់ទី២ ឃុំមង់រៀវ

មាត្រា២. រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អភិបាល នៃគណៈអភិបាលខេត្តត្បូងឃ្មុំ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ទីស្នាក់ការសម្តេចនាយករដ្ឋមន្ត្រី
-ទីស្នាក់ការឧបនាយករដ្ឋមន្ត្រី
-អ្នកមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ថ្ងៃសុក្រ ៨ កើត ខែ ទុតិយាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១៨
នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៧២៤២ អនក្រ.ត

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ
រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

សម្រេច

មាត្រា១.. បំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន១៨រូប ដែលមានស្នាដៃល្អ ក្នុងការចូលរួមជួយកសាងសមិទ្ធផលនានា នៅវត្តមង្គលបូរី ហៅ វត្តមង់ ឃុំមង់រៀវ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ កន្លងមក ដូចមានរាយនាមខាងក្រោម ៖

ក-មេដាយធ្លាក់ស្ថាបនាជាតិ

១-លោក	ម៉ូវ	ឆុង	សប្បុរសជន
២-លោក	ស៊ីម	ហ៊ីយអូន	សប្បុរសជន
៣-លោក	ឆ្លូ	យូឆាយ	សប្បុរសជន
៤-លោក	ចិន	ប៊ុនថាប់	សប្បុរសជន
៥-លោក	ហ៊ាង	ហេង	សប្បុរសជន
៦-ឧបាសិកា	ហ៊ុ	គឹមហ៊ាន	សប្បុរសជន
៧-អ្នកស្រី	ហ៊ុ	គឹមហេង	សប្បុរសជន
៨-អ្នកស្រី	ឡាយ	សុឆារី	សប្បុរសជន
៩-លោក	ហេង	ឌៀន	សប្បុរសជន
១០-លោក	ហ្គ្លូ	អ៊ាងគង់	សប្បុរសជន
១១-អ្នកស្រី	ស៊ីវ	រ៉ុង	សប្បុរសជន

១២-លោក	ទីម	សុភា	សប្បុរសជន
១៣-លោក	ឈាង	ចន់ហុង	សប្បុរសជន
១៤-លោក	ទីម	សុភក្ត្រ	សប្បុរសជន
១៥-លោក	ទីម	សុភាព	សប្បុរសជន
១៦-ឧបាសិកា	ហេង	ឈុនរេង	សប្បុរសជន

ខ-មេជាយសំរីទ្ធស្ថាបនាជាតិ

១-ឧបាសក	ម៉ែត	សយ	គណៈកម្មការវត្ត
២-ឧបាសក	ជន	ឌៀន	គណៈកម្មការវត្ត

មាត្រា២. រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អភិបាល នៃគណៈអភិបាលខេត្តត្បូងឃ្មុំ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមការកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ធកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ធកាល័យឧបនាយករដ្ឋមន្ត្រី
-អ្នកមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ថ្ងៃសុក្រ ៤ រោចខែកត្តិក ឆ្នាំ ២០១៧ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស.២៥៦២
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៨
នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១២៤៣.អនក្រ.គត

អនុក្រឹត្យ
ស្តីពីការផ្ទេរមេដាយការងារ
រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

សម្រេច

មាត្រា១. បំពាក់ **មេដាយមាសការងារ** ជូនលោក **ជ័យ សៀន** សមាជិកក្រុមប្រឹក្សាឃុំមង់រៀវ ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ចបម្រើប្រទេសជាតិ និងបានចូលរួមជួយកសាងសមិទ្ធផលនានា នៅវត្តមង្គលបូរី ហៅ វត្តមង់ ឃុំមង់រៀវ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ កន្លងមក ។

មាត្រា២. រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អភិបាល នៃគណៈអភិបាលខេត្តត្បូងឃ្មុំ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃសុក្រ ៨ កើត ខែ ទុតិយាសាឍ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស. ២៥៦២
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១៨
នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការវាំងរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៧៤៤.អនក្រ.តត

អនុក្រឹត្យ
ស្តីពីការជូនមេដាយមុនីសាវ៉ាត់ណា
រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ /រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១. បំពាក់ **មេដាយមុនីសាវ៉ាត់ណា** ថ្នាក់ **ធិបឌិន្ត** ចំនួន ២៧គ្រឿង ជូនមន្ត្រីរាជការ និងសប្បុរសជន ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមជួយកសាង និងអភិវឌ្ឍ ស្រុកកំចាយមារ ខេត្តព្រៃវែង កន្លងមក ដូចមានរាយនាមខាងក្រោម៖

១-លោក	ឆុក	គឹមស៊ី	អនុប្រធានមន្ទីរពាណិជ្ជកម្ម
២-លោក	សៀក	ម៉េងហាំង	សប្បុរសជននៅភ្នំពេញ
៣-លោកស្រី	សេង	ឌារី	អនុប្រធាននាយកដ្ឋាន
៤-លោក	ហេង	សុផាន់ណារ៉ិទ្ធ	សប្បុរសជននៅភ្នំពេញ
៥-លោក	សុន	ពិសី	សប្បុរសជននៅភ្នំពេញ
៦-លោក	ធឿន	សុធិន	សប្បុរសជននៅភ្នំពេញ
៧-លោក	ឃីម	ហៅ១	ប្រធានការិយាល័យពន្ធដារស្រុកពាមរក៍
៨-លោក	រស់	សំអាង	ប្រធានការិយាល័យពន្ធដារស្រុកកំពង់ត្របែក
៩-លោក	ខុន	ឈុសល	ប្រធានការិយាល័យពន្ធដារស្រុកព្រះស្តេច
១០-លោក	ឆុក	យូហេង	ជំនួយការសម្តេចតេជោ
១១-លោក	ឆេង	ឌុន្នី	សប្បុរសជននៅភ្នំពេញ
១២-លោក	ឆុក	ឆុង	សប្បុរសជននៅភ្នំពេញ
១៣-លោក	ហ៊ីម	ឌួញ	ប្រធានសាខាពន្ធដារខេត្តព្រៃវែង
១៤-លោក	សេង	ណៅជ៉ិញ	លេខាធិការក្រុមប្រឹក្សាខេត្ត

១៥-លោក	ភៅ	សីហា	សប្បុរសជននៅភ្នំពេញ
១៦-លោក	១	ឈីណា	អនុប្រធានការិយាល័យភូមិបាលស្រុកស្វាយអន្ទរ
១៧-លោក	អ៊ុន	ស៊ីណាង	សប្បុរសជននៅភ្នំពេញ
១៨-លោក	គឹម	១សនា	សប្បុរសជននៅភ្នំពេញ
១៩-លោក	ឌៀង	ត្រាកដ	សប្បុរសជននៅភ្នំពេញ
២០-អ្នកស្រី	នួន	មុនីចន្ធា	សប្បុរសជននៅភ្នំពេញ
២១-លោក	ឌាន	សុតំត្រ	សប្បុរសជននៅព្រៃវែង
២២-លោក	១	ចិន្ធា	សប្បុរសជននៅភ្នំពេញ
២៣-ឯកឧត្តម	១	សុខមេ	សប្បុរសជននៅភ្នំពេញ
២៤-លោកជំទាវ	ម្យ៉ាន	សុខនី	សប្បុរសជននៅភ្នំពេញ
២៥-លោកស្រី	សុន	ជ១	អនុប្រធានមន្ទីរសុរិយោដីខេត្តព្រៃវែង
២៦-លោក	ស៊ីន	ចំន្ទ	សប្បុរសជននៅភ្នំពេញ
២៧-លោក	គម	១	មន្ត្រីភូមិបាលស្រុកស្វាយអន្ទរ

មាត្រា ២. រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលនៃគណៈអភិបាលខេត្តព្រៃវែង និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ថ្ងៃ២ រ ១១ កើត ខែ១ ២០១១ ឆ្នាំ២ រ ០ ១ ០ ១ ០ ១

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ..៧៤.ម.ជ..រដក្រ.ត

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ
រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១. បំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន ១១រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមជួយកសាង និងអភិវឌ្ឍ ស្រុកកំចាយមារ ខេត្តព្រៃវែង ក្នុងមក ដូចមានរាយនាមខាងក្រោម៖

ក-មេដាយមាសស្ថាបនាជាតិ

១-ព្រះតេជគុណ **ហ្សឹក ឆ្ឍ** អនុក្រុមប្រឹក្សាព្រះមេគណខេត្តកំពង់ស្ពឺ

ខ-មេដាយសំរ៉ៃទ្ធស្ថាបនាជាតិ

១-ឧបាសក	**ស៊ីម**	**ស៊ាម**	៧-ឧបាសក	**ជ្ជាត់**	**សាន**
